## តារាងប្រៀបធៀប

## អនុស្សរណៈនៃការយោគយល់ ស្ដីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត

| ចំណុចខុសគ្នា | សេចក្ដីព្រាងអនុស្សរណៈដែលភាគីកម្ពុជាបញ្ជូនទៅ | សេចក្ដីព្រាងបកអនុស្សរណៈដែលភាគីអារ៉ាប៊ីសាអូឌីតបញ្ជូនមកវិញ |
|---|---|---|
| **ចំណងជើង** | - ឈ្មោះចំណងជើង ៖ *អនុស្សរណៈនៃការយោគយល់ ស្ដីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់*<br>- រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត តទៅនេះហៅដោយឡែកថា «ភាគី» និងហៅជារួមថា «គូភាគី»<br>- ដោយមានបំណងពង្រឹង និងបង្កើនទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត ក្នុងក្របខណ្ឌនៃគោលការណ៍គោរពអធិបតេយ្យ សមភាព និងផលប្រយោជន៍ទៅវិញទៅមក<br>- ដោយមើលឃើញភាពចាំបាច់ក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង និងបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ស្របតាមច្បាប់ជាតិ និងកាតព្វកិច្ចអន្តរជាតិរបស់គូភាគី សំដៅធានាស្ថិរភាព ការពារសន្តិសុខ និងលើកកម្ពស់សុខមាលភាពប្រជាពលរដ្ឋនៃគូភាគី<br>- ដោយពិចារណាលើកាតព្វកិច្ចស្របតាមច្បាប់អន្តរជាតិរបស់គូភាគី និងសេរីភាពរបស់ប្រជាពលរដ្ឋ នៃប្រទេសទាំងពីរ បានព្រមព្រៀងដូចខាងក្រោម៖ | - ឈ្មោះចំណងជើង៖ *កិច្ចព្រមព្រៀង ស្ដីពីកិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខ*<br>- រដ្ឋាភិបាលនៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត~~កម្ពុជា~~ និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា~~អារ៉ាប៊ីសាអូឌីត~~ តទៅនេះហៅ~~ដោយឡែក~~ថា ~~«ភាគី» និងហៅជារួមថា~~ «គូភាគី»<br>- ~~ដោយមានបំណងពង្រឹង និងបង្កើនទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត ក្នុងក្របខណ្ឌនៃគោលការណ៍គោរពអធិបតេយ្យ សមភាព និងផលប្រយោជន៍ទៅវិញទៅមក~~<br>- ~~ដោយមើលឃើញភាពចាំបាច់ក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង និងបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ស្របតាមច្បាប់ជាតិ និងកាតព្វកិច្ចអន្តរជាតិរបស់គូភាគី សំដៅធានាស្ថិរភាព ការពារសន្តិសុខ និងលើកកម្ពស់សុខមាលភាពប្រជាពលរដ្ឋនៃគូភាគី~~<br>- ~~ដោយពិចារណាលើកាតព្វកិច្ចស្របតាមច្បាប់អន្តរជាតិរបស់គូភាគី និងសេរីភាពរបស់ប្រជាពលរដ្ឋ នៃប្រទេសទាំងពីរ~~<br>- ក្នុងស្មារតីពង្រឹងបន្ថែមនូវចំណងទាក់ទងរវាងភាគីទាំងពីរ |

| | | |
|---|---|---|
| | | - ដោយមានបំណងបង្កើតកិច្ចសហការលើការប្រយុទ្ធប្រឆាំងបទល្មើស<br>- ដោយទទួលស្គាល់នូវផលប្រយោជន៍ទៅវិញទៅមកនៃកិច្ចសហការនេះ<br>- អនុលោមតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន នៃគូភាគី និង<br>- ក្នុងស្មារតីគោរពអធិបតេយ្យជាតិរៀងខ្លួន<br>បានព្រមព្រៀងដូចខាងក្រោម៖ |
| **មាត្រា១** | **វិស័យនៃកិច្ចសហប្រតិបត្តិការ**<br>- គូភាគីត្រូវសហការតាមគ្រប់មធ្យោបាយ ដើម្បីទបស្កាត់ បង្ក្រាប និងស៊ើបអង្កេតបទល្មើស ដោយអនុលោមតាមច្បាប់ជាតិនៃប្រទេសរៀងៗខ្លួន និងសន្ធិសញ្ញាអន្តរជាតិ ដែលខ្លួនជាភាគី រួមមានជាអាទិ៍ ដូចខាងក្រោម៖<br>ក) ឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង<br>ខ) ការផលិត ចរាចរ និងការជួញដូរគ្រឿងញៀនដោយខុសច្បាប់ និងសារធាតុប៉ះពាល់សរសៃប្រសាទ<br>គ) ការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា<br>ឃ) បទល្មើសបច្ចេកវិទ្យាព័ត៌មាន<br>ង) ការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ ជាពិសេសស្ត្រី និងកុមារ<br>ច) ការរត់ពន្ធជនទេសន្តរប្រវេសន្ត និងទេសន្តប្រវេសន៍ខុសច្បាប់<br>ឆ) ការសម្អាតប្រាក់<br>ជ) សកម្មភាពភេរវកម្ម រួមទាំងការផ្តល់ហិរញ្ញប្បទានភេរវកម្ម | ~~វិស័យនៃកិច្ចសហប្រតិបត្តិការ~~<br>- គូភាគី~~ត្រូវសហការតាមគ្រប់មធ្យោបាយ ដើម្បីទបស្កាត់ បង្ក្រាប និងស៊ើបអង្កេតបទល្មើស ដោយអនុលោមតាមច្បាប់ជាតិនៃប្រទេសរៀងៗខ្លួន និងសន្ធិសញ្ញាអន្តរជាតិ ដែលខ្លួនជាភាគី រួមមានជាអាទិ៍~~ ព្រមព្រៀងសហការប្រយុទ្ធប្រឆាំងបទល្មើសគ្រប់ទម្រង់ ជាពិសេសបទល្មើស ដូចខាងក្រោម៖<br>១- ~~ឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង~~ អំពើភេរវកម្ម និងការផ្តល់ហិរញ្ញប្បទានភេរវកម្ម (ចំណុចនេះមានដូចចំណុច «ជ»)<br>២- ~~ការផលិត ចរាចរ និងការជួញដូរគ្រឿងញៀនដោយខុសច្បាប់ និងសារធាតុប៉ះពាល់សរសៃប្រសាទ~~ ឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង ( ចំណុចនេះមានដូចចំណុច «ក»)<br>៣- ~~ការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា~~ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង<br>៤- ~~បទល្មើសបច្ចេកវិទ្យាព័ត៌មាន~~ បទល្មើសគ្រឿងញៀន សារធាតុញៀន និងសារធាតុគីមីផ្សំ |

| | | |
|---|---|---|
| | ឈ) ការក្លែងក្រដាសប្រាក់ លិខិតឆ្លងដែន ទិដ្ឋាការ និងឯកសារផ្លូវការផ្សេងទៀត<br>ញ) ការជួញដូរខុសច្បាប់នូវអាវុធ គ្រាប់រំសេវ គ្រឿងផ្ទុះ សារធាតុនុយក្លេអ៊ែរ ជីវសាស្ត្រ គីមីសាស្ត្រ វិទ្យុសកម្ម និងសារធាតុពុល<br>ដ) ការរត់ពន្ធទំនិញជាប់ពន្ធគយគ្រប់ប្រភេទ និងគ្រឿងស្រវឹង ផលិតផលថ្នាំជក់ និងប្រេងឥន្ធនៈ។ | ៥- ~~ការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ ជាពិសេសស្ត្រី និងកុមារ~~ បទល្មើសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>៦- ~~ការរត់ពន្ធជនទេសន្តប្រវេសន្ត និងទេសន្តប្រវេសន៍ខុសច្បាប់~~ ការសម្អាតប្រាក់ (ចំណុចនេះមានដូចចំណុច «ឆ»)<br>៧- ~~សកម្មភាពភេរវកម្ម រួមទាំងការផ្តល់ហិរញ្ញប្បទានភេរវកម្ម~~ អំពើពុករលួយ<br>៨- ~~ការក្លែងក្រដាសប្រាក់ លិខិតឆ្លងដែន ទិដ្ឋាការ និងឯកសារផ្លូវការផ្សេងទៀត~~ អំពើឆបោក (ក្នុងចំណុច «គ» របស់កម្ពុជាបន្ថែមពាក្យ «តាមប្រព័ន្ធបច្ចេកវិទ្យា»)<br>៩- ~~ការជួញដូរខុសច្បាប់នូវអាវុធ គ្រាប់រំសេវ គ្រឿងផ្ទុះ សារធាតុនុយក្លេអ៊ែរ ជីវសាស្ត្រ គីមីសាស្ត្រ វិទ្យុសកម្ម និងសារធាតុពុល~~ ការក្លែងបន្លំឯកសារ និងរូបិយបណ្ណ<br>១០- ~~ការរត់ពន្ធទំនិញជាប់ពន្ធគយគ្រប់ប្រភេទ និងគ្រឿងស្រវឹង ផលិតផលថ្នាំជក់ និងប្រេងឥន្ធនៈ។~~ ការលួច ឬ ការរត់ពន្ធមធ្យោបាយដឹកជញ្ជូន ឬការជួញដូរដោយខុសច្បាប់ពាក់ព័ន្ធផ្សេងទៀត<br>១១- ការ~~ជួញដូរខុសច្បាប់នូវ~~លួច ឬ រត់ពន្ធអាវុធ គ្រាប់រំសេវ ឬ គ្រឿងផ្ទុះ ~~សារធាតុនុយក្លេអ៊ែរ ជីវសាស្ត្រ គីមីសាស្ត្រ វិទ្យុសកម្ម និងសារធាតុពុល~~ ឬការជួញដូរដោយខុសច្បាប់ពាក់ព័ន្ធ |

| | | |
|---|---|---|
| | | ផ្សេងទៀត។ (ចំណុចនេះមានភាពស្រដៀងគ្នាខ្លះនឹងចំណុច «ញ»)<br>១២-ការលួចសម្ភារៈគីមី~~សាស្ត្រ~~ ~~សារធាតុ~~នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ~~និងសារធាតុពុល~~ឬ ការជួញដូរដោយខុសច្បាប់ពាក់ព័ន្ធផ្សេងទៀត (ចំណុចនេះ ខាងអារ៉ាប៊ីសាអូឌីត បំបែកចេញពីចំណុច «ញ» ទៅជាពីរមាត្រា គឺ ១១ និង១២)<br>១៣-ការប៉ះពាល់ដល់បុគ្គលភាព ឬ ទ្រព្យសម្បត្តិ<br>១៤-អំពើជួញដូរមនុស្ស (ចំណុចនេះមាននៅចំណុច «ង»)<br>១៥-អំពើអន្តោប្រវេសន៍ខុសច្បាប់ (ចំណុចនេះមាននៅចំណុច «ច»)<br>១៦-ការលួច ឬ ការជួញដូរវត្ថុបុរាណ និងរបស់របរដែលមានតម្លៃជាសិល្បៈ វប្បធម៌ និង ប្រវត្តិសាស្ត្រ ឬ ការជួញដូរដោយខុសច្បាប់ពាក់ព័ន្ធផ្សេងទៀត<br>១៧-បទល្មើសបច្ចេកវិទ្យា~~ព័ត៌មាន~~ (ចំណុចនេះមាននៅ ចំណុច «ឃ»)<br>១៨-បទល្មើសបរិស្ថាន។ |
| មាត្រា ២ | **ទម្រង់ និងលក្ខខណ្ឌនៃកិច្ចសហប្រតិបត្តិការ**<br>១- កិច្ចសហប្រតិបត្តិការអាចធ្វើឡើងតាមគ្រប់រូបភាព រួមមានជាអាទិ៍ការផ្លាស់ប្តូរព័ត៌មាន ការតាមស្វែងរក និងការកំណត់អត្តសញ្ញាណបុគ្គល និងវិធានការផ្សេងៗទៀត ស្របតាមគោលបំណងនៃអនុស្សរណៈនេះ។ | ~~ទម្រង់ និងលក្ខខណ្ឌនៃកិច្ចសហប្រតិបត្តិការ~~<br>- គូភាគីត្រូវសហការប្រយុទ្ធប្រឆាំងបទល្មើសដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងនេះ តាមរយៈមធ្យោបាយ និងនីតិវិធីដូចខាងក្រោម៖<br>១- ~~កិច្ចសហប្រតិបត្តិការអាចធ្វើឡើងតាមគ្រប់រូបភាព រួមមានជាអាទិ៍ការផ្លាស់ប្តូរព័ត៌មាន ការស្វែងរក និងការកំណត់អត្ត~~ |

| | | |
|---|---|---|
| | ២- រាល់ការស្នើសុំព័ត៌មាន ឬវិធានការផ្សេងៗ អនុលោមតាមអនុស្សរណៈនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ជាអក្សរអង់គ្លេស តាមផ្លូវការទូត ឬតាមរយៈការទំនាក់ទំនងផ្ទាល់ ដោយអាជ្ញាធរមានសមត្ថកិច្ចនៃគូភាគី ដោយត្រូវភ្ជាប់ជាមួយឯកសារយោងពាក់ព័ន្ធ។ ក្នុងករណីបន្ទាន់ សំណើអាចធ្វើឡើងដោយផ្ទាល់មាត់ ហើយត្រូវធ្វើជាលាយលក្ខណ៍អក្សរឱ្យលើសរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ។<br>៣- ភាគីទទួលសំណើមានសិទ្ធិស្នើសុំព័ត៌មានបន្ថែម ពីភាគីម្ចាស់សំណើ ប្រសិនបើយល់ឃើញថាមានភាពចាំបាច់សម្រាប់ការអនុវត្តសំណើឱ្យបានសមស្រប។<br>៤- ទោះបីមិនមានការស្នើសុំក៏ដោយ ភាគីម្ខាងអាចបញ្ជូនព័ត៌មានទៅភាគីម្ខាងទៀតបាន ប្រសិនបើមានមូលដ្ឋានជឿជាក់ថា ព័ត៌មាននោះមានប្រយោជន៍ដល់ភាគីម្ខាងទៀត។<br>៥- សំណើសុំត្រូវមាន៖<br>ក) ឈ្មោះអាជ្ញាធរនៃភាគីម្ចាស់សំណើ និងឈ្មោះអាជ្ញាធរនៃភាគីទទួលសំណើ<br>ខ) ព័ត៌មានលម្អិតអំពីករណីដែលត្រូវស្នើសុំ<br>គ) គោលបំណង និងមូលហេតុនៃការស្នើសុំ<br>ឃ) សេចក្តីពិពណ៌នាអំពីជំនួយដែលស្នើសុំ<br>ង) កម្រិតនៃភាពបន្ទាន់<br>ច) ព័ត៌មានផ្សេងទៀត ដែលអាចជួយឱ្យការអនុវត្តសំណើប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។<br>៦- ប្រសិនបើការអនុវត្តតាមការស្នើសុំជំនួយ ឬសកម្មភាពសហប្រតិបត្តិការណាមួយ ធ្វើឱ្យប៉ះពាល់ដល់អធិបតេយ្យ ឬសន្តិសុខ | ~~សញ្ញាណបុគ្គល និងវិធានការផ្សេងទៀត ស្របតាមគោលបំណងនៃអនុស្សរណៈនេះ។~~ ភាគីនីមួយៗត្រូវជូនដំណឹងភាគីខាងទៀតនូវព័ត៌មានដែលខ្លួនមាន ពាក់ព័ន្ធអំពើល្មើសសំដៅប្រឆាំងភាគីម្ខាងទៀត ទោះបានប្រព្រឹត្តរួចហើយក្តី ឬ កំពុងរៀបចំផែនការមិនថានៅលើទឹកដី នៃភាគីណាមួយ ឬភាគីទីបី។<br>២- ~~រាល់ការស្នើសុំព័ត៌មាន ឬវិធានការផ្សេងៗ អនុលោមតាមអនុស្សរណៈនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ជាអក្សរអង់គ្លេស តាមផ្លូវការទូត ឬតាមរយៈការទំនាក់ទំនងផ្ទាល់ ដោយអាជ្ញាធរមានសមត្ថកិច្ចនៃគូភាគី ដោយត្រូវភ្ជាប់ជាមួយឯកសារយោងពាក់ព័ន្ធ។ ក្នុងករណីបន្ទាន់ សំណើអាចធ្វើឡើងដោយផ្ទាល់មាត់ ហើយត្រូវធ្វើជាលាយលក្ខណ៍អក្សរឱ្យលើសរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ។~~ ការអនុវត្តការចែកចាយដោយមានការត្រួតពិនិត្យរវាងគូភាគីក្នុងករណីពាក់ព័ន្ធនឹងគ្រឿងញៀន សារធាតុញៀន និងសារធាតុគីមីផ្សំ។<br>៣- ~~ភាគីទទួលសំណើមានសិទ្ធិស្នើសុំព័ត៌មានបន្ថែមពីភាគីម្ចាស់សំណើ ប្រសិនបើយល់ឃើញថាមានភាពចាំបាច់សម្រាប់ការអនុវត្តសមណើឱ្យបានសមស្រប។~~ ការស្រាវជ្រាវរកបុគ្គលដែលកំពុងតាមចាប់ និងការផ្លាស់ប្តូរព័ត៌មាន និងទិន្នន័យផ្ទាល់ខ្លួនរបស់បុគ្គលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសដូចមានចែងខាងលើ រួមទាំងព័ត៌មានធនាគារ និងហិរញ្ញវត្ថុ និងការផ្តល់យុត្តិកម្មពាក់ព័ន្ធផ្សេងទៀត។<br>៤- ~~ទោះបីមិនមានការស្នើសុំក៏ដោយ ភាគីម្ខាងអាចបញ្ជូនព័ត៌មានទៅភាគីម្ខាងទៀតបាន ប្រសិនបើមានមូលដ្ឋានជឿជាក់ថា~~ |

| | | |
|---|---|---|
| | ឬផ្ទុយនឹងច្បាប់ជាតិ កាតព្វកិច្ចអន្តរជាតិ ឬផលប្រយោជន៍ចាំបាច់ផ្សេងទៀតរបស់ភាគីម្ខាង ភាគីដែលទទួលរងផលប៉ះពាល់នោះ អាចបដិសេធមិនអនុវត្តសំណើនោះ គ្រង់ផ្នែកខ្លះ ឬទាំងស្រុង ឬអាចអនុវត្តសំណើក្រោមលក្ខខណ្ឌជាក់លាក់ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភាគីម្ចាស់សំណើ។ | ~~ព័ត៌មាននោះមានប្រយោជន៍ដល់ភាគីម្ខាងទៀត។~~ ការផ្លាស់ប្តូរព័ត៌មានភ្លាមៗលើបុគ្គល ក្រុម និងអង្គការភេរវកម្ម ជាពិសេសព័ត៌មានពាក់ព័ន្ធរចនាសម្ព័ន្ធ សកម្មភាព ប្រភពមូលនិធិ និងមធ្យោបាយទំនាក់ទំនង។<br>៥- ~~សំណើសុំត្រូវមាន៖~~<br>~~ក) ឈ្មោះអាជ្ញាធរនៃភាគីម្ចាស់សំណើ និងឈ្មោះអាជ្ញាធរនៃភាគីទទួលសំណើ~~<br>~~ខ) ព័ត៌មានលម្អិតអំពីករណីដែលត្រូវស្នើសុំ~~<br>~~គ) គោលបំណង និងមូលហេតុនៃការស្នើសុំ~~<br>~~ឃ) សេចក្តីពិពណ៌នាអំពីជំនួយដែលស្នើសុំ~~<br>~~ង) កម្រិតនៃភាពបន្ទាន់~~<br>~~ច) ព័ត៌មានផ្សេងទៀត ដែលអាចជួយឱ្យការអនុវត្តសំណើប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។~~<br>ការវាយតម្លៃការគំរាមកំហែងបង្កដោយអំពើភេរវកម្ម និងការផ្តល់ហិរញ្ញប្បទានភេរវកម្ម ឧក្រិដ្ឋកម្ម មានអង្គការចាត់តាំង បទល្មើសគ្រឿងញៀន សារធាតុញៀន និងសារធាតុគីមីផ្សំ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានពាក់ព័ន្ធ សំដៅបង្កើតយន្តការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសទាំងនេះ។<br>៦- ~~ប្រសិនបើការអនុវត្តតាមការស្នើសុំជំនួយ ឬសកម្មភាពសហប្រតិបត្តិការណាមួយ ធ្វើឱ្យប៉ះពាល់ដល់អធិបតេយ្យ ឬសន្តិសុខ ឬផ្ទុយនឹងច្បាប់ជាតិ កាតព្វកិច្ចអន្តរជាតិ ឬផលប្រយោជន៍ចាំបាច់ផ្សេងទៀតរបស់ភាគីម្ខាង ភាគីដែលទទួលរងផលប៉ះពាល់នោះ អាចបដិសេធមិនអនុវត្តសំណើនោះ គ្រង់ផ្នែកខ្លះ~~ |

| | | |
|---|---|---|
| | | ~~ឬទាំងស្រុង ឬអាចអនុវត្តសំណើក្រោមលក្ខខណ្ឌជាក់លាក់បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភាគីម្ចាស់សំណើ។~~ ការផ្លាស់ប្តូរព័ត៌មាន និងជំនាញពាក់ព័ន្ធការការពារមធ្យោបាយដឹកជញ្ជូន និងអ្នកដំណើរ។<br>៧- ការផ្លាស់ប្តូរព័ត៌មាន និងជំនាញពាក់ព័ន្ធមធ្យោបាយ និងបច្ចេកទេសថ្មីបម្រើដល់ការប្រព្រឹត្តបទល្មើស ក៏ដូចជាវិធីសាស្រ្តបង្រ្កាបបទល្មើសទាំងនេះ។<br>៨- ការផ្លាស់ប្តូរអត្ថបទច្បាប់ បទដ្ឋានគតិយុត្ត និងសំដៅអត្ថបទបោះពុម្ពពាក់ព័ន្ធការបង្រ្កាប បទល្មើស ចេញផ្សាយដោយស្ថាប័នមានសមត្ថកិច្ច នៃគូភាគី។<br>៩- ការផ្លាស់ប្តូរឈ្មោះបុគ្គល ដែលត្រូវបានផ្តន្ទាទោសពីបទល្មើសប្រព្រឹត្តប្រឆាំងភាគីម្ខាងទៀត ក៏ដូចជាឈ្មោះបុគ្គលកំពុងឃុំរង់ចាំការជំនុំជម្រះពាក់ព័ន្ធបទល្មើសធ្ងន់ធ្ងរ ប្រព្រឹត្តដោយពលរដ្ឋនៃភាគីម្ខាងទៀត។<br>១០-គូភាគីអាចសហការលើវិស័យសន្តិសុខផ្សេងទៀត ផ្អែកតាមការព្រមព្រៀងទៅវិញទៅមក ប្រសិនបើកិច្ចសហការទាំងនោះស្របជាមួយគោលបំណងនៃកិច្ចព្រមព្រៀង។ |
| មាត្រា ៣ | **ដែនកំណត់លើការប្រើប្រាស់ព័ត៌មាន និងឯកសារ**<br>១- គូភាគីព្រមព្រៀងគ្នាថាព័ត៌មាន និងទិន្នន័យបុគ្គល ដែលបានបញ្ជូនស្របតាមអនុស្សរណៈនេះ ត្រូវប្រើប្រាស់សម្រាប់គោលបំណងដូចមានចែងក្នុងអនុស្សរណៈនេះតែប៉ុណ្ណោះ ដោយត្រូវគោរពសិទ្ធិបុគ្គល អនុលោមតាមច្បាប់ជាតិ និងសន្ធិសញ្ញាសិទ្ធិមនុស្សពាក់ព័ន្ធ ដែលខ្លួនជាភាគី។ | ~~ដែនកំណត់លើការប្រើប្រាស់ព័ត៌មាន និងឯកសារ~~<br>~~១- គូភាគីព្រមព្រៀងគ្នាថាព័ត៌មាន និងទិន្នន័យបុគ្គល ដែលបានបញ្ជូនស្របតាមអនុស្សរណៈនេះ ត្រូវប្រើប្រាស់សម្រាប់គោលបំណងដូចមានចែងក្នុងអនុស្សរណៈនេះតែប៉ុណ្ណោះ ដោយត្រូវគោរពសិទ្ធិបុគ្គល អនុលោមតាមច្បាប់ជាតិ និងសន្ធិសញ្ញា សិទ្ធិមនុស្សពាក់ព័ន្ធ ដែលខ្លួនជាភាគី។~~ |

| | | |
|---|---|---|
| | ២- ទិន្នន័យបុគ្គល និងជាពិសេសព័ត៌មានសម្ងាត់ដែលបានផ្លាស់ប្តូររវាងគូភាគី ត្រូវការពារស្របតាមបទដ្ឋាន ដូចគ្នាទៅនឹងការអនុវត្តចំពោះទិន្នន័យជាតិ និងអនុលោមតាមច្បាប់ជាតិ ឬបទប្បញ្ញត្តិរបស់គូភាគីស្តីពីទិន្នន័យ និងព័ត៌មាន។<br>៣- គូភាគីត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់ នូវទិន្នន័យព័ត៌មានឯកសារ និងសម្ភារទាំងឡាយ ដែលគូភាគីបានចែករំលែកទៅវិញទៅមក។ កាតព្វកិច្ចនៃការរក្សាការសម្ងាត់នេះ ត្រូវបន្តមានអានុភាពអនុវត្តដដែល ទោះបីក្រោយការបញ្ចប់ នៃអនុស្សរណៈនេះក៏ដោយ។ | ~~២- ទិន្នន័យបុគ្គល និងជាពិសេសព័ត៌មានសម្ងាត់ដែលបានផ្លាស់ប្តូររវាងគូភាគី ត្រូវការពារស្របតាមបទដ្ឋាន ដូចគ្នាទៅនឹងការអនុវត្តចំពោះទិន្នន័យជាតិ និងអនុលោមតាមច្បាប់ជាតិ ឬបទប្បញ្ញត្តិរបស់គូភាគីស្តីពីទិន្នន័យ និងព័ត៌មាន។~~<br>~~៣- គូភាគីត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់ នូវទិន្នន័យព័ត៌មានឯកសារ និងសម្ភារទាំងឡាយ ដែលគូភាគីបានចែករំលែកទៅវិញទៅមក។ កាតព្វកិច្ចនៃការរក្សាការសម្ងាត់នេះ ត្រូវបន្តមានអានុភាពអនុវត្តដដែល ទោះបីក្រោយការបញ្ចប់ នៃអនុស្សរណៈនេះក៏ដោយ។~~<br>- ក្នុងករណីភាគីណាមួយឃុំខ្លួនពលរដ្ឋនៃភាគីម្ខាងទៀត ក្រោមបទល្មើសដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ស្ថាប័នមានសមត្ថកិច្ច នៃភាគីឃុំខ្លួន ឬ ចាប់ខ្លួន ត្រូវជូនដំណឹងភ្លាមមកភាគីដែលពលរដ្ឋរបស់ខ្លួនត្រូវបានឃុំខ្លួន ឬចាប់ខ្លួន។ |
| មាត្រា ៤ | **អង្គភាពទំនាក់ទំនងសម្រាប់ការអនុវត្តអនុស្សរណៈ**<br>១- អាជ្ញាធរមានសមត្ថកិច្ចសម្រាប់អនុវត្តអនុស្សរណៈនេះ មានដូចខាងក្រោម៖<br>ក) សម្រាប់ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា៖ អគ្គលេខាធិការដ្ឋាន<br>ខ) សម្រាប់ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត៖ ……………………..<br>២- ក្នុងរយៈពេល ៣០(សាមសិបថ្ងៃ) គិតចាប់ពីថ្ងៃអនុស្សរណៈនេះចូលជាធរមាន គូភាគីត្រូវផ្លាស់ប្តូរបញ្ជីឈ្មោះអង្គភាពចំណុះ | ~~**អង្គភាពទំនាក់ទំនងសម្រាប់ការអនុវត្តអនុស្សរណៈ**~~<br>***សម្រាប់មាត្រា ៤ របស់ភាគីកម្ពុជា ភាគីអារ៉ាប៊ីសាអ៊ីឌីតលើកយកទៅដាក់នៅមាត្រា ១០ របស់ខ្លួន***<br>- គូភាគីត្រូវសហការបណ្តុះបណ្តាលលើវិស័យសន្តិសុខ តាមរយៈសកម្មភាពដូចខាងក្រោម៖<br>១- កម្មវិធី និងវគ្គបណ្តុះបណ្តាល<br>២- ការផ្លាស់ប្តូរជំនួប និងដំណើរទស្សនកិច្ច<br>៣- សន្និសីទ ការតាំងពិព័រណ៍ និងសិក្ខាសាលា<br>៤- ការផ្លាស់ប្តូរសម្ភារៈឧបករណ៍ជំនួយដល់ការបណ្តុះបណ្តាល និងអនុវត្តជាក់ស្តែងដែលខ្លួនមាន។ |

| | | |
|---|---|---|
| | ដែលមានសមត្ថកិច្ចទាក់ទងផ្ទាល់លើការងារអនុវត្តបទប្បញ្ញត្តិនៃអនុស្សរណៈនេះ និងបង្កើតច្រកទំនាក់ទំនងពាក់ព័ន្ធ។<br>៣- គូភាគីត្រូវជូនដំណឹងទៅវិញទៅមកភ្លាមៗអំពីការផ្លាស់ប្តូរអង្គភាពចំណុះដែលមានសមត្ថកិច្ចទាក់ទងផ្ទាល់ លើការងារអនុវត្តបទប្បញ្ញត្តិនៃអនុស្សរណៈនេះ។ | |
| មាត្រា ៥ | **ការពិគ្រោះយោបល់**<br>- ភាគីទាំងពីរត្រូវធ្វើការពិគ្រោះយោបល់គ្នា នៅរាល់ពេលមានតម្រូវការ ឬក្នុងករណីខ្លះ ត្រូវធ្វើឡើងរៀងរាល់ឆ្នាំ ដើម្បីវាយតម្លៃ ការវិវត្តក្នុងបរិបទនៃអនុស្សរណៈនេះ ព្រមទាំងដើម្បីកែសម្រួល និងពង្រឹងកិច្ចសហប្រតិបត្តិការនេះ។ | ~~ការពិគ្រោះយោបល់~~<br>- ~~ភាគីទាំងពីរត្រូវធ្វើការពិគ្រោះយោបល់គ្នា នៅរាល់ពេលមានតម្រូវការ ឬក្នុងករណីខ្លះ ត្រូវធ្វើឡើងរៀងរាល់ឆ្នាំ ដើម្បីវាយតម្លៃ ការវិវត្តក្នុងបរិបទនៃអនុស្សរណៈនេះ ព្រមទាំងដើម្បីកែសម្រួល និងពង្រឹងកិច្ចសហប្រតិបត្តិការនេះ។~~<br>- ភាគីនីមួយៗអាចបដិសេធក្នុងការអនុវត្តកិច្ចសហការ ដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ ទោះទាំងស្រុងក្តី ឬ ផ្នែកខ្លះក្តីក្នុងករណីកិច្ចសហការនេះ៖<br>១- ធ្វើឱ្យប៉ះពាល់ដល់អធិបតេយ្យ ឬ សន្តិសុខរបស់ខ្លួន<br>២- ផ្ទុយនឹងច្បាប់ជាតិ<br>៣- ប៉ះពាល់ដល់ដំណើរការស៊ើបអង្កេត ឬ កិច្ចដំណើរការនីតិវិធីនានា ឬ<br>៤- មានទំនាស់ជាមួយនឹងកិច្ចដំណើរការនីតិវិធីតុលាការដែលបានអនុវត្តក្នុងទឹកដីរបស់ខ្លួន។ |

| | | |
|---|---|---|
| មាត្រា ៦ | **ការដោះស្រាយវិវាទ**<br>- វិវាទដែលអាចកើតចេញពីការបកស្រាយ ឬការអនុវត្តអនុស្សរណៈនេះ ត្រូវដោះស្រាយក្នុងស្មារតីមិត្តភាព តាមរយៈការពិគ្រោះយោបល់រវាងអាជ្ញាធរមានសមត្ថកិច្ច ដូចមានចែងក្នុងមាត្រា៦ វាក្យខណ្ឌទី១ និងតាមរយៈការចចាតាមផ្លូវការទូត។ | ~~ការដោះស្រាយវិវាទ~~<br>- ~~វិវាទដែលអាចកើតចេញពីការបកស្រាយ ឬការអនុវត្តអនុស្សរណៈនេះ ត្រូវដោះស្រាយក្នុងស្មារតីមិត្តភាព តាមរយៈការពិគ្រោះយោបល់រវាងអាជ្ញាធរមានសមត្ថកិច្ច ដូចមានចែងក្នុងមាត្រា៦ វាក្យខណ្ឌទី១ និងតាមរយៈការចចាតាមផ្លូវការទូត។~~<br>- គូភាគីត្រូវរក្សាការសម្ងាត់នៃព័ត៌មានដែលបានផ្លាស់ប្តូរស្របតាមកិច្ចព្រមព្រៀងនេះ។ ព័ត៌មានទាំងនេះ អាចប្រើប្រាស់សម្រាប់គោលបំណងដូចបានកំណត់ ហើយភាគីនីមួយៗ មិនអាចផ្ទេរ ឬចែករំលែកជូនភាគីទីបី ដោយគ្មានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីភាគីផ្តល់បាននោះឡើយ។ គូភាគីត្រូវបន្តអនុវត្តបទប្បញ្ញត្តិនៃមាត្រានេះ ទោះបីកិច្ចព្រមព្រៀងនេះត្រូវបានបញ្ចប់ក៏ដោយក្តី។ |
| មាត្រា ៧ | **ទំនាក់ទំនងនៃអនុស្សរណៈនេះជាមួយសន្ធិសញ្ញាអន្តរជាតិដទៃទៀត**<br>- អនុស្សរណៈនេះមិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ច ដែលកើតចេញពីសន្ធិសញ្ញាអន្តរជាតិដទៃទៀត ដែលភាគីនីមួយៗបានចុះហត្ថលេខារួចហើយនោះឡើយ។ | ~~ទំនាក់ទំនងនៃអនុស្សរណៈនេះជាមួយសន្ធិសញ្ញាអន្តរជាតិដទៃទៀត~~<br>~~អនុស្សរណៈ~~កិច្ចព្រមព្រៀងនេះមិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី ស្របតាមសន្ធិសញ្ញាទ្វេភាគី ឬពហុភាគីដែលខ្លួនជាភាគីនោះឡើយ~~ដែលកើតចេញពីសន្ធិសញ្ញាអន្តរជាតិដទៃទៀត ដែលភាគីនីមួយៗបានចុះហត្ថលេខារួចហើយនោះឡើយ។~~ |
| មាត្រា ៨ | **ការចំណាយផ្សេងៗ**<br>- ការចំណាយផ្សេងៗសម្រាប់ដំណើរការសំណើក្រោមអនុស្សរណៈនេះ ជាបន្ទុករបស់ភាគីស្នើសុំ ឬធ្វើតាមការព្រមព្រៀងរបស់គូភាគី។ | ~~ការចំណាយផ្សេងៗ~~<br>- ~~ការចំណាយផ្សេងៗសម្រាប់ដំណើរការសំណើក្រោមអនុស្សរណៈនេះ ជាបន្ទុករបស់ភាគីស្នើសុំ ឬធ្វើតាមការព្រមព្រៀងរបស់គូភាគី។~~ វិវាទដែលកើតចេញពីការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះត្រូវដោះស្រាយតាមរយៈការទាក់ទងដោយផ្ទាល់រវាងគូភាគី។ ក្នុងករណីគ្មានការព្រមព្រៀង វិវាទទាំងនេះត្រូវដោះ |

| | | |
|---|---|---|
| | | ស្រាយតាមរយៈមធ្យោបាយការទូត ដោយមិនត្រូវបញ្ជូនទុកជូនស្ថាប័នតុលាការ សាលាក្តី ឬភាគីទីបី ដោះស្រាយនោះឡើយ។<br>*ចំពោះមាត្រា ៨ របស់ភាគីកម្ពុជា ខាងអារ៉ាប៊ីសាអូឌីតលើកយកទៅដាក់នៅមាត្រា ៩ របស់ខ្លួន*<br>ខាងភាគីអារ៉ាប៊ីសាអូឌីតកែសម្រួលមាត្រានេះថ្មី |
| មាត្រា៩ | **អវសានប្បញ្ញត្តិ**<br>១- អនុស្សរណៈនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយគូភាគី។<br>២- អនុស្សរណៈនេះមានសុពលភាពរយៈពេល ៣(បី)ឆ្នាំ។ ភាគីម្ខាងអាចជូនដំណឹងភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ តាមរយៈស្ថានទូត ក្នុងពេលណាក៏បាន ប្រសិនបើខ្លួនមានបំណងបញ្ចប់អនុស្សរណៈនេះ។ ក្នុងករណីនេះ អនុស្សរណៈនេះនឹងបញ្ចប់ក្នុងរយៈពេល ៣(បី)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង។ ការបញ្ចប់អនុស្សរណៈនេះ មិនមានផលប៉ះពាល់ដល់ការអនុវត្តភារកិច្ចដែលមិនទាន់បានបញ្ចប់ទាំងឡាយណា ដែលបានព្រមព្រៀងកន្លងមកនោះទេ។<br>៣- ក្រោយអនុស្សរណៈនេះចូលជាធរមាន ភាគីម្ខាងអាចស្នើភាគីម្ខាងទៀតសុំធ្វើវិសោធនកម្ម ឬបំពេញបន្ថែមលើអត្ថបទអនុស្សរណៈនេះបាន។ វិសោធនកម្ម ឬការបំពេញបន្ថែមត្រូវមានការព្រមព្រៀងរវាងគូភាគី និងត្រូវចូលជាធរមានស្របតាមនីតិវិធី ដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ។<br>អនុស្សរណៈនៃការយោគយល់នេះ ត្រូវបានចុះហត្ថលេខា នៅថ្ងៃទី………..ខែ…………..ឆ្នាំ២០២……………..នៅរាជធានី…. | *ចំពោះមាត្រា ៩ របស់ភាគីកម្ពុជា ខាងអារ៉ាប៊ីសាអូឌីតលើកយកទៅដាក់នៅមាត្រា ១០ របស់ខ្លួន*<br>- ការចំណាយនានាពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងនេះ ជាបន្ទុករបស់ភាគីដែលទទួលបន្ទុកចំណាយលើទឹកដីរបស់ខ្លួន លើកលែងតែគូភាគីមានការព្រមព្រៀងផ្សេងពីនេះ។<br><br>*ក្នុងចំណុច ៣ របស់ភាគីកម្ពុជា ខាងអារ៉ាប៊ីសាអូឌីតលើកយកទៅដាក់នៅមាត្រាទី១២ (ផ្នែកចុងក្រោយ) របស់ខ្លួន* |

| | | |
|---|---|---|
| | ……នៃព្រះរាជាណាចក្រកម្ពុជា/ព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត។ អនុស្សរណៈនេះធ្វើឡើងជា ២(ពីរ)ច្បាប់ដើម ជាអក្សរខ្មែរ និងអក្សរអង់គ្លេស ដែលសំណៅនៃច្បាប់ដើមនីមួយៗមានតម្លៃស្មើគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នា សំណៅជាភាសាអង់គ្លេសត្រូវយកជាគោល៕<br><br>ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត<br><br>ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ……………………… | |
| មាត្រា ១០<br>(បន្ថែមថ្មីរបស់អារ៉ាប៊ីសាអូឌីត) | | ១- ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកអនុវត្តកិច្ចព្រមព្រៀងនេះរួមមាន៖<br>- សម្រាប់រដ្ឋាភិបាលនៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត៖ ក្រសួងមហាផ្ទៃ និងក្រសួងសន្តិសុខជាតិ<br>- សម្រាប់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា៖……………<br>២- ភាគីនីមួយៗត្រូវជូនដំណឹងភាគីម្ខាងទៀត តាមរយៈមធ្យោបាយការទូត អំពីការផ្លាស់ប្តូរស្ថាប័នសមត្ថកិច្ចរបស់ខ្លួន។<br>៣- ស្ថាប័នមានសមត្ថកិច្ចត្រូវចាត់តាំងជាលាយលក្ខណ៍អក្សរ នូវមន្ត្រីទំនាក់ទំនងដោយផ្ទាល់ និងមធ្យោបាយទំនាក់ទំនង ដើម្បីសម្រួលដល់កិច្ចសហការលើវិស័យដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងនេះ។<br>៤- ភាសាអារ៉ាប់ និងភាសាអង់គ្លេស ជាភាសាដែលត្រូវប្រើប្រាស់សម្រាប់ការអនុវត្តកិច្ចព្រមព្រៀងនេះ។ |

| | | |
|---|---|---|
| **មាត្រា ១១**<br>(បន្ថែមថ្មីរបស់អារ៉ាប៊ីសាអូឌីត) | | - ក្នុងករណីចាំបាច់ គូភាគីអាចបង្កើតគណៈកម្មាធិការជំនាញដែលមានសមាសភាពមកពីប្រទេសទាំងពីរ ដែលមានជំនាញប្រយុទ្ធប្រឆាំងបទល្មើស និងបណ្តុះបណ្តាលលើវិស័យសន្តិសុខ ដើម្បីពិភាក្សាអំពីរបៀបនៃកិច្ចសហការ ក្នុងវិស័យសន្តិសុខនៃប្រទេសទាំងពីរ សំដៅដាក់ចេញអនុសាសន៍ចាំបាច់បម្រើដល់ការពង្រឹងកិច្ចព្រមព្រៀងនេះ និងដើម្បីដាក់ជូនស្ថាប័នមានសមត្ថកិច្ច នៃគូភាគី។ ក្នុងករណីចាំបាច់ គណៈកម្មាធិការនេះអាចជួបប្រជុំនៅក្នុងប្រទេសនៃភាគីនីមួយៗ តាមវិធីផ្លាស់ប្តូរវេនគ្នា ទៅតាមការស្នើសុំរបស់គូភាគី។ |
| **មាត្រា១២**<br>(បន្ថែមថ្មីរបស់អារ៉ាប៊ីសាអូឌីត) | | ១- កិច្ចព្រមព្រៀងនេះមានសុពលភាពអនុវត្តគិតចាប់ពីការផ្លាស់ប្តូរការជូនដំណឹងចុងក្រោយរវាងគូភាគី តាមរយៈមធ្យោបាយការទូតបញ្ជាក់អំពីការបំពេញបែបបទនីតិវិធីច្បាប់ជាតិចាំបាច់នានា។<br>២- កិច្ចព្រមព្រៀងនេះអាចធ្វើវិសោធនកម្ម តាមការព្រមព្រៀងទៅវិញទៅមក។ អត្ថបទវិសោធនកម្ម ត្រូវមានសុពលភាពអនុវត្តស្របតាមនីតិវិធី ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។<br>៣- កិច្ចព្រមព្រៀងនេះបន្តមានសុពលភាពអនុវត្តដោយគ្មានពេលកំណត់ លុះត្រាតែភាគីណាមួយជូនដំណឹងជាលាយលក្ខណ៍អក្សរតាមរយៈមធ្យោបាយការទូត បញ្ជាក់អំពីបំណងបញ្ចប់កិច្ចព្រមព្រៀងនេះ ជូនភាគីម្ខាងទៀត យ៉ាងតិច ០៦ខែ មុនពេលកាលបរិច្ឆេទបញ្ចប់កិច្ចព្រមព្រៀង។ |

| | | |
|---|---|---|
| **ផ្នែកចុងក្រោយ**<br>(បន្ថែមថ្មីរបស់អារ៉ាប៊ីសាអូឌីត) | | ធ្វើនៅទីក្រុង............... នៅថ្ងៃទី......../......../<br>ជា XX ច្បាប់ដើម ជាអក្សរអារ៉ាប់ និងអង់គ្លេស ដែលសំណៅនៃច្បាប់ដើមនីមួយៗមានតម្លៃស្មើគ្នា។<br><br>តំណាងរដ្ឋាភិបាល ព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត<br><br>តំណាងរដ្ឋាភិបាល ព្រះរាជាណាចក្រកម្ពុជា<br><br>រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ<br><br>រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ |